

# ព្រះគ្រីស្ទបានប្រទានអាហារដល់មនុស្សស្រេកឃ្លាន

*នៅថ្ងៃមួយ ព្រះយេស៊ូវ គ្រីស្ទ បានបង្រៀនដល់ក្រុមមនុស្សមួយក្រុមដែលមានចំនួនច្រើនជាង ៥០០០ នាក់ ។ នៅពេលដែលហួសពេល នោះពួកសិស្សចង់បញ្ជូនមនុស្សឲ្យត្រឡប់ទៅផ្ទះវិញដើម្បីទទួលទានអាហារ ។ ព្រះយេស៊ូវមិនចង់ឲ្យពួកគេចាកចេញទៅទេ ។ ទ្រង់ចង់ប្រទានអាហារដល់ពួកគេ ។ ប៉ុន្តែពួកសិស្សមានតែនំប៉័ងប្រាំដុំ និងត្រីពីរប៉ុណ្ណោះ ។*

*ព្រះយេស៊ូវបានប្រសិទ្ធពរអាហារនោះ ។ បន្ទាប់មកពួកសិស្សបានចែកអាហារទៅមនុស្សទាំងនោះ ។ គ្រប់គ្នាបានទទួលអាហារគ្រប់គ្រាន់ដើម្បីទទួលទាន ។ វាជាអព្ភូតហេតុមួយ !*

អ្នកអាចអានដំណើររឿងនេះនៅក្នុង លូកា ៩:១៤–២១ ។

## ខ្ញុំអាចចែកចាយ

តើអ្នកអាចចែកចាយជាមួយនរណាខ្លះ ?

សូមអធិស្ឋាន និងធ្វើផែនការមួយដើម្បីជួយពួកគេ ។



អនុវត្តតាមផែនការរបស់អ្នក !

កាត់ប័ណ្ណនេះចេញដើម្បីជាការរំឭកដល់អ្នកឲ្យបន្តជួយដូចជាព្រះយេស៊ូ ។



កុមារមួយក្រុមនៅ រដ្ឋយូថាហ៍ ស.រ.អា បានរៀបចំការបរិច្ចាគស្រោមជើងដើម្បីជួយដល់សប្បុរសធម៌ក្នុងតំបន់ ដែលបម្រើដល់មនុស្សគ្មានទីជម្រក ។ ពួកគេបានចែកចាយប័ណ្ណប្រកាស ។ ប៉ុន្មានថ្ងៃក្រោយមក ពួកគេបានប្រមូលបានស្រោមជើង និងប្រាក់ដើម្បីទិញស្រោមជើងបន្ថែមទៀតផងដែរ ។ ពួកគេអាចបរិច្ចាគស្រោមជើងចំនួន ៧៥០ គូរ !

តើអ្នកកំពុងតែព្យាយាមជួយអ្នកដទៃដូចដែលព្រះយេស៊ូវបានធ្វើដោយរបៀបណា ? សូមសរសេរ ហើយប្រាប់មកពួកយើង ។

រូបភាពមកពី GoodSalt, Inc ។